# ការជូនដំណឹងសំខាន់



សម្រាប់បុគ្គលដែលរស់នៅក្នុងគ្រួសារដែលមានតែឪពុកឬម្តាយតែម្នាក់
(គ្រួសារដែលមិនទទួលបានអត្ថប្រយោជន៍ពិសេសសម្រាប់គ្រួសារដែលមានតែឪពុកឬម្តាយតែម្នាក់)

## អត្ថប្រយោជន៍ជំនួយការរស់នៅពិសេសសម្រាប់គ្រួសារដែលមានកូន

សូមធ្វើការណែនាំ **<u>អត្ថប្រយោជន៍ពិសេស</u>** សម្រាប់គ្រួសារដែលមានកូន!

## 1. បុគ្គលដែលមានសិទ្ធិទទួលបាន

បុគ្គលដែលបំពេញតាមលក្ខខណ្ឌតម្រូវ (1) ឬ (2) ខាងក្រោម (*** មិនរាប់បញ្ចូលបុគ្គលដែលបានទទួលអត្ថប្រយោជន៍សម្រាប់គ្រួសារដែលមានតែឪពុកឬម្តាយតែម្នាក់ឡើយ**)

(1) បុគ្គល**<u>ដែលមានសិទ្ធិទទួលបានអត្ថប្រយោជន៍ជំនួយការរស់នៅពិសេសសម្រាប់គ្រួសារដែលមានកូននៅក្នុងឆ្នាំ 2022 (អត្ថប្រយោជន៍កាលពីឆ្នាំមុន)</u>**
(បុគ្គលដែលបានទទួល ឬបដិសេធមិនទទួលអត្ថប្រយោជន៍កាលពីឆ្នាំមុន ដោយមិនគិតថាមានឬគ្មានការតម្រូវឱ្យមានការដាក់ពាក្យស្នើសុំឬអត់នោះទេ)

(2)
- ឪពុក-ម្តាយ/អាណាព្យាបាលដែលចិញ្ចឹម **<u>កូនម្នាក់/ច្រើននាក់ដែលមានអាយុក្រោម 18 ឆ្នាំ *</u>** (ឬកូនម្នាក់/ច្រើននាក់ដែលមានពិការភាព **<u>មានអាយុក្រោម 20 ឆ្នាំ</u>**) គិតត្រឹមថ្ងៃទី31 ខែមីនា ឆ្នាំ2023 និង
- បុគ្គលដែលប្រាក់ចំណូលរបស់ខ្លួនត្រូវបានផ្លាស់ប្តូរភ្លាមៗ ចាប់តាំងពីថ្ងៃទី1 ខែមករា ឆ្នាំ 2023 និងបុគ្គលដែលប្រាក់ចំណូលរបស់ខ្លួនក្នុងពេលនេះ **<u>ដូចគ្នាទៅនឹងកម្រិតប្រាក់ចំណូលរបស់អ្នកដែលត្រូវបានលើកលែងពន្ធលើពលរដ្ឋ</u>**

(* សិទ្ធិទទួលបានត្រូវបានកំណត់ចំពោះគ្រួសារដែលមានកូនទើបនឹងកើត ។ល។ ដែលមានកូនកើតនៅថ្ងៃ ឬមុនថ្ងៃទី29 ខែកុម្ភៈ ឆ្នាំ2024)

## 2. ចំនួនប្រាក់អត្ថប្រយោជន៍

**50,000 យ៉េន ក្នុងកូនមួយនាក់**

- ដើម្បីទទួលបានអត្ថប្រយោជន៍ <u>អាចមាន</u> ឬ <u>គ្មានការតម្រូវ</u>ឱ្យមានពាក្យស្នើសុំ។
សូមត្រួតពិនិត្យនីតិវិធីសម្រាប់ការទទួលបានអត្ថប្រយោជន៍នៅទំព័រខាងខ្នង សម្រាប់ព័ត៌មានបន្ថែម។

* ប្រសិនបើមានសំណួរណាមួយ សូមទូរស័ព្ទទៅលេខខាងក្រោម។

- **មជ្ឈមណ្ឌលសេវាអតិថិជនរបស់ទីភ្នាក់ងារកុមារនិងគ្រួសារ**
(ម៉ោង៖ 9:00 ព្រឹក – 6:00 ល្ងាច ថ្ងៃធ្វើការ)
**0120-400-903**
ទាក់ទងទៅកាន់សាលាក្រុង/ស្រុកក្នុងមូលដ្ឋានរបស់អ្នកដែលធ្វើការពាក់ព័ន្ធនឹង អត្ថប្រយោជន៍ជំនួយការរស់នៅពិសេសសម្រាប់គ្រួសារដែលមានកូន (ក្រៅពីគ្រួសារដែលមានតែឪពុកឬម្តាយតែម្នាក់) សម្រាប់ព័ត៌មានបន្ថែមអំពីរបៀបដាក់ពាក្យស្នើសុំ។

令和５年度子育て世帯生活支援特別給付金　で検索

## 3. នីតិវិធីសម្រាប់ការទទួលបានអត្ថប្រយោជន៍

### I. បុគ្គលដែលមានសិទ្ធិទទួលបានអត្ថប្រយោជន៍ជំនួយការរស់នៅពិសេសសម្រាប់គ្រួសារមានប្រាក់ចំណូលទាបដែលមានកូនសម្រាប់ឆ្នាំ2022 ( គ្រួសារមានប្រាក់ចំណូលទាបដែលមានកូន តែមិនមែនជាគ្រួសារដែលមានតែឪពុកឬម្ដាយតែម្នាក់ )

▶ **ពុំចាំបាច់មានពាក្យស្នើសុំ** ដើម្បីទទួលបានអត្ថប្រយោជន៍ឡើយ។

▶ ក្រុង/ស្រុកក្នុងមូលដ្ឋានរបស់អ្នកនឹងផ្ទេរអត្ថប្រយោជន៍ដោយផ្ទាល់ចូលទៅក្នុងគណនីដែលបានកំណត់សម្រាប់អត្ថប្រយោជន៍ជំនួយការរស់នៅពិសេសសម្រាប់គ្រួសារមានប្រាក់ចំណូលទាបដែលមានកូន ឆ្នាំ2022 ( ឧទាហរណ៍ គណនីដែលបានប្រើសម្រាប់ដាក់ប្រាក់ឧបត្ថម្ភដល់កុមារ ឬប្រាក់ឧបត្ថម្ភសម្រាប់ការចិញ្ចឹមកូនមានពិការភាព នៅក្នុងខែមេសា ឆ្នាំ2022 ) ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

[ចំណាំ]

* បុគ្គលដែលពុំមានបំណងចង់ទទួលអត្ថប្រយោជន៍ ត្រូវធ្វើការជូនដំណឹងអំពីការបដិសេធរបស់ខ្លួនទៅកាន់ស្រុក/ក្រុងក្នុងមូលដ្ឋាន។
* ប្រសិនបើអាចមានលទ្ធភាពដែលការទូទាត់ប្រាក់អត្ថប្រយោជន៍ ត្រូវបានធ្វើឡើងពុំត្រឹមត្រូវ ដូចជា ដោយសារគណនីដែលបានកំណត់សម្រាប់អត្ថប្រយោជន៍ជំនួយការរស់នៅពិសេសសម្រាប់គ្រួសារមានប្រាក់ចំណូលទាបដែលមានកូន ឆ្នាំ2022 ត្រូវបានបិទជាដើម ដូច្នេះ អ្នកត្រូវប្រាកដថាបានធ្វើការផ្លាស់ប្ដូរគណនីដែលបានកំណត់នោះ ឬចាត់វិធានការបង្ការជាមុនទៅតាមការចាំបាច់។

### II. បុគ្គលផ្សេងទៀតក្រៅពីបុគ្គលខាងលើ ( ឧ.ទា.៖ បុគ្គលដែលមានការផ្លាស់ប្ដូរប្រាក់ចំណូលភ្លាមៗ )

▶ **ចាំបាច់ត្រូវមានពាក្យស្នើសុំ** ដើម្បីទទួលបានអត្ថប្រយោជន៍។

▶ សូមបំពេញទម្រង់បែបបទពាក្យស្នើសុំនេះ (រួមបញ្ចូលទាំងព័ត៌មានគណនីធនាគាររបស់អ្នកផង ) និងប្រគល់ទម្រង់បែបបទនេះរួមគ្នាជាមួយនឹងឯកសារដែលចាំបាច់ **ដោយផ្ទាល់ទៅកាន់សាលាក្រុងក្នុងមូលដ្ឋានរបស់អ្នក** ឬ **តាមសំបុត្រប្រៃសណីយ៍**។

▶ ពាក្យស្នើសុំនឹងត្រូវធ្វើការផ្ទៀងផ្ទាត់ ហើយអត្ថប្រយោជន៍នឹងត្រូវដាក់បញ្ចូលទៅក្នុងគណនីដែលបានបញ្ជាក់សម្រាប់អ្នកដាក់ពាក្យស្នើសុំដែលបំពេញតាមលក្ខខណ្ឌដែលបានតម្រូវ។

ពាក្យស្នើសុំ
អត្ថប្រយោជន៍

( 1 ) ពាក្យស្នើសុំអត្ថប្រយោជន៍

ដាក់ពាក្យស្នើសុំដោយផ្ទាល់ទៅកាន់សាលាក្រុង/ស្រុកក្នុងមូលដ្ឋានរបស់អ្នក ឬ តាមសំបុត្រប្រៃសណីយ៍។

( 2 ) អត្ថប្រយោជន៍ត្រូវបានផ្ទេរទៅកាន់គណនីធនាគារ

សាលាក្រុង/
ស្រុកក្នុង
មូលដ្ឋាន

**!** សូមមានការប្រុងប្រយ័ត្នចំពោះ **ករណីឆបោកដែលអាចកើតមានចំពោះការផ្ទេរប្រាក់តាមធនាគារ និង ករណីឆបោកព័ត៌មានផ្ទាល់ខ្លួន** ពាក់ព័ន្ធនឹងអត្ថប្រយោជន៍ជំនួយការរស់នៅពិសេសសម្រាប់គ្រួសារដែលមានកូន។

ទាក់ទងទៅកាន់សាលាក្រុង/ស្រុកក្នុងមូលដ្ឋានរបស់អ្នក ប៉ុស្តិ៍នគរបាលដែលនៅជិតបំផុត ឬខ្សែទូរស័ព្ទប្រឹក្សាយោបល់ជាមួយប៉ូលិសដែលបានកំណត់ (#9110) ប្រសិនបើអ្នកទទួលបានការហៅទូរស័ព្ទដែលមានការសង្ស័យ ឬការឆ្លើយតបតាមសំបុត្រប្រៃសណីយ៍ទៅកាន់ផ្ទះ ឬកន្លែងធ្វើការរបស់អ្នកពីនរណាម្នាក់ដែលបានអះអាងថាជាបុគ្គលិករដ្ឋបាលស្រុកឬក្រុង ឬថាជាតំណាងទីភ្នាក់ងារកុមារនិងគ្រួសារ។